ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៨ លេខ ១០

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC



ក

ស

វ

## Work Activities

ប្រចាំខែតុលា ឆ្នាំ២០១៥



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងអនុក្រឹត្យស្តីពីបុននីតិសម្បទា និងការជម្រះបញ្ជីក្នុងវិស័យមូលបត្រ | ១ |
| ២- | ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែកញ្ញា ឆ្នាំ២០១៥ | ៣ |
| ៣- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១១ |

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# បុននីតិសម្បទា និងការជម្រះបញ្ជី ក្នុងវិស័យមូលបត្រ

កាលពីថ្ងៃទី៨ និងថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៥ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **អ៊ូច ថោងសេង** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) និង ឯកឧត្តម **លីវ សុវណ្ណា** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីបុននីតិសម្បទា និងការជម្រះបញ្ជីក្នុងវិស័យមូលបត្រ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងគណៈកម្មការមូលបត្រកម្ពុជា។

គណៈកម្មការមូលបត្រកម្ពុជា(គ.ម.ក.) បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីបុននីតិសម្បទា និងការជម្រះបញ្ជីក្នុងវិស័យមូលបត្រ ក្នុងគោលបំណងបង្ការក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ ឬការអនុញ្ញាត ឬការទទួលស្គាល់ពី គ.ម.ក. និងបុគ្គលបោះផ្សាយលក់មូលបត្រជាសាធារណៈពីក្ស័យធន ព្រមទាំងផ្តល់ក្របខ័ណ្ឌគតិយុត្តឲ្យ គ.ម.ក. សម្របសម្រួលការធ្វើបុននីតិសម្បទា និងជម្រះបញ្ជីក្រុមហ៊ុន បោះផ្សាយ លក់មូលបត្រជាសាធារណៈ ដោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចឲ្យទាន់ពេលវេលា និងមានប្រសិទ្ធភាពដើម្បីរក្សា និងបង្កើនទំនប់ចិត្តរបស់វិនិយោគិននៅក្នុងទីផ្សារមូលបត្រ។




ស្ថិតក្នុងចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ពិសេស “យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១១-២០២០” ដែលបានកំណត់នូវគោលដៅរយៈពេលវែងយ៉ាងច្បាស់លាស់ ក្នុងគោលបំណងគាំទ្រប្រកបដោយសមធម៌ និងចីរភាពនូវការកេណ្ឌប្រមូលធនធាន ការបែងចែកធនធានហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព និងសេដ្ឋកិច្ច ដែលមានមូលដ្ឋានធំទូលាយ និងរឹងមាំ ការអភិវឌ្ឍវិស័យមូលបត្រ ដែលវិស័យមូលបត្រជាវិស័ថ្មីមួយ និងជាផ្នែកមួយនៃវិស័យហិរញ្ញវត្ថុ ក្រៅពីវិស័យធនាគារនិងវិស័យធានារ៉ាប់រង

ដែលចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ក៏ត្រូវបានចាត់ទុកជាយុទ្ធសាស្រ្តគន្លឹះមួយ។ ក្នុងទិសដៅនេះ គណៈកម្មការមូលបត្រកម្ពុជា ត្រូវបានសម្ពោធជាផ្លូវការនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ ហើយទីផ្សារមូលបត្រកម្ពុជា ត្រូវបានសម្ពោធដាក់ឲ្យដំណើរការនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១។

នៅក្នុងវិស័យមូលបត្រ បុគ្គលដែលមានធុរកិច្ចពាក់ព័ន្ធនឹងវិស័យមូលបត្រ ត្រូវបំពេញលក្ខខណ្ឌទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ដើម្បីធានានូវដំណើរការប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព តម្លាភាព និងភាពរឹងមាំក្នុងការប្រកបធុរកិច្ច។ ករណីក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ ឬការអនុញ្ញាត ឬការទទួលស្គាល់ពី គ.ម.ក. ឲ្យធ្វើធុរកិច្ចពាក់ព័ន្ធនឹងវិស័យមូលបត្រ និងបុគ្គលបោះផ្សាយលក់មូលបត្រជាសាធារណៈជួបនូវស្ថានភាព៖

ក-ស្ថានភាពដែលក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ មិនអាចមានលទ្ធភាពក្នុងការបំពេញតាមលក្ខខណ្ឌមូលធនអប្បបរមា ដូចបានកំណត់ដោយ គ.ម.ក.។

ខ-ស្ថានភាពដែលក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ យល់ឃើញថាហានិភ័យ ឬហានិភ័យដែលមានចែងក្នុងផែនការគ្រប់គ្រងហានិភ័យ ដែលតម្រូវឲ្យ គ.ម.ក. អាចកើតឡើងជាក់ស្តែង ឬស្ថានភាពដែលក្រុមហ៊ុន ឬបុគ្គលបោះផ្សាយអាចប្រឈមនឹងហានិភ័យ ដែលក្រុមហ៊ុន ឬបុគ្គលបោះផ្សាយមាន ឬអាចជួបប្រទះបញ្ហាហិរញ្ញវត្ថុ ដែលចាំបាច់ត្រូវតែធ្វើបុនរ្នីតិសម្បទា។

គ-ស្ថានភាពដែល គ.ម.ក. យល់ឃើញថា ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយមាន ឬអាចជួបប្រទះបញ្ហាហិរញ្ញវត្ថុ ដែលចាំបាច់ត្រូវធ្វើបុនរ្នីតិសម្បទា។

ឃ-ស្ថានភាពដែល គ.ម.ក. ឬក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ យល់ឃើញថា ក្រុមហ៊ុននឹងក្លាយជាអសាធនីយ។

បញ្ហាហិរញ្ញវត្ថុរបស់បុគ្គលទាំងនេះអាចកើតឡើងដោយសារកត្តាអភិបាលកិច្ចរបស់ខ្លួន និងកត្តាឥទ្ធិពលពីខាងក្រៅដូចជាវិបត្តិសេដ្ឋកិច្ចជាសាកលជាដើម ដែលការណ៍នេះជាក្តីបារម្ភរបស់វិនិយោគគិន ពាក់ព័ន្ធនឹងទ្រព្យរបស់ខ្លួននៅក្នុងក្រុមហ៊ុនទាំងនោះ និងជះឥទ្ធិពលយ៉ាងខ្លាំងដល់ទំនុកចិត្តលើទីផ្សារមូលបត្រកម្ពុជា(១)។

អង្គប្រជុំជាបន្តបន្ទាប់បានពិនិត្យពិភាក្សាលើសេចក្តីព្រាងឯកសារនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុរបស់សេចក្តីព្រាងអនុក្រឹត្យស្តីពីបុនរ្នីតិសម្បទា និងការជម្រះបញ្ជីក្នុងវិស័យមូលបត្រ។

# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែកញ្ញា ឆ្នាំ២០១៥*



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌កម្ពុជា **ប្រចាំខែកញ្ញា ឆ្នាំ២០១៥**នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ (ECOSOCC) នៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៥ ក្រោមអធិបតីភាព ឯកឧត្តម **ឌុយ ឆៅ** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពី អនុប្រធាន សមាជិក សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែសីហាឆ្នាំ២០១៥សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង ០,៣% ធៀបនឹងខែមុន និងកើនឡើង ០,៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល១២ខែ)។

**តារាង១.១.** បម្រែបម្រួលថ្លៃធៀបនឹងខែដូចគ្នាឆ្នាំមុនសម្រាប់ក្រុមទំនិញនិងមុខទំនិញមួយចំនួន

| *ក្រុមទំនិញ:* | | *មុខទំនិញ:* | |
|---|---|---|---|
| សំលៀកបំពាក់ និងស្បែកជើង: | +៥,៥% | ត្រីស្រស់: | +៨,៦% |
| ភោជនីយដ្ឋាន: | +៤,២% | បន្លែ: | +៧,៦% |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់: | +៣,៨% | អង្ករ: | +២,៥% |
| ម្ហូបអាហារ: | +៣,៦% | សាច់មាន់: | +២,២% |
| ការកម្សាន្ត និងវប្បធម៌: | +១,៨% | ផ្លែឈើ: | +២,០% |
| សុខាភិបាល: | +១,២% | សាច់ជ្រូក: | +១,១% |

**តារាង១.២. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១៣–២០១៥**

| ឆ្នាំ | ធៀបនឹងខែ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា^P | វិច្ឆិកា^P | ធ្នូ^P | ប្រចាំឆ្នាំ^P |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៥ | ដូចគ្នាឆ្នាំមុន | ០,៤% | ១,៦% | ១,១% | ១,៣% | ១,០% | ០,៧% | ០,៨% | ០,៨% | ០,៩% | ០,៩% | ១,០% | ១,១% | ១,០% |
| | មុន | -០,៤% | ១,២% | ០,១% | ០,៧% | ០,១% | ០,២% | ០,៦% | ០,៣% | ០,២% | -០,៤% | -០,៧% | -០,៧% | |
| ២០១៤ | ដូចគ្នាឆ្នាំមុន | ៤,៥% | ៤,៣% | ៥,០% | ៤,៩% | ៤,៦% | ៤,៩% | ៤,២% | ៤,១% | ៣,៦% | ២,៩% | ២,៤% | ២,៥% | ៤,០% |
| | មុន | ០,២% | ០ | ០,៥% | ០,៥% | ០,៣% | ០,៥% | ០,៤% | ០,៣% | ០,២% | -០,៤% | -០,៨% | ០,៧% | |
| ២០១៣ | ដូចគ្នាឆ្នាំមុន | ១,៨% | ១,៧% | ១,០% | ១,០% | ២,៨% | ២,៩% | ៤,០% | ៣,៣% | ៣,៩% | ៤,២% | ៤,១% | ៤,៧% | ៣,០% |
| | មុន | ០,៣% | ០,២% | -០,១% | ០,៦% | ០,៧% | ០,២% | ១% | ០,៤% | ០,៧% | ០,២% | -០,៣% | ០,៥% | |

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

P: **តួលេខខែ**តុលា វិច្ឆិកា ធ្នូនិងប្រចាំ**ឆ្នាំ២០១៥ ជាតួលេខព្យាករ (តាមវិធីសាស្ត្រ** DECOMPOSITION)

ក្រាហ្វ ១.១. ចលនានិងបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់







**តារាង១.៣.** អត្រាប្តូរប្រាក់

| *ប្រភេទ* | កញ្ញា២០១៥ | សីហា២០១៥ | កញ្ញា២០១៤ | *ប្រភេទ* | កញ្ញា២០១៥ | សីហា២០១៥ | កញ្ញា២០១៤ |
|---|---|---|---|---|---|---|---|
| **៛/ដុល្លារ** | ៤០៧៦៛/$ | ៤០៨១៛/$ | ៤០៨៥៛/$ | **បាត/ដុល្លារ** | ៣៦,៤១បាត/$ | ៣៥,៨១បាត/$ | ៣២,៣៧បាត/$ |
| **៛/បាត** | ១១២៛/បាត | ១១៤៛/បាត | ១២៦៛/បាត | **ដុង/ដុល្លារ** | ២២៤៨៦ដុង/$ | ២២៤៦០ដុង/$ | ២១២២០ដុង/$ |
| **៛/ដុង** | ០,១៨១៛/ដុង | ០,១៨៩៛/ដុង | ០,១៩៣៛/ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់រតនាគារជាតិអគ្គនាយកដ្ឋានគយនិងរដ្ឋាករនិងអគ្គនាយកដ្ឋានពន្ធដារក្នុងខែកញ្ញាឆ្នាំ២០១៥ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម៖

**២.១. ចំណូលថវិកាជាតិ**(តួលេខរតនាគារជាតិ) : អនុវត្តបាន ១១០៤ពាន់លានរៀល(*មធ្យមប្រចាំខែ ១០៦% នៃផែនការ*) ក្នុងនោះចំណូលចរន្ត១០៩២,៦ ពាន់លានរៀល(*មធ្យមប្រចាំខែ ១០២% នៃផែនការ*) និងចំណូលមូលធន១១,៤ពាន់លានរៀល ។

ក្រាហ្វ ២.១. ចំណូលថវិកាជាតិ ឆ្នាំ ២០១៣-២០១៥

(ពាន់លានរៀល)




- ➢បើធៀបនឹងខែមុនចំណូលថវិកាជាតិកើនឡើង១២,៤% និងកើនឡើង៣០% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ➢នៅក្នុងចំណូលចរន្ត:
  - ✓ចំណូលសារពើពន្ធមានចំនួន៩២២,៥ ពាន់លានរៀល កើនឡើង១៦,៧%ធៀបនឹងខែមុននិងកើនឡើង២៣,៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន ។
  - ✓ចំណូលមិនមែនសារពើពន្ធមានចំនួន ១៧០,១ពាន់លានរៀល កើនឡើង៥៣%ធៀបនឹងខែមុននិងកើនឡើង ៦៤,៨%ធៀបនឹងខែដូចគ្នាឆ្នាំមុន(តួលេខ រតនាគារជាតិ)។

តារាង២.១. មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ

| ចំណូលសារពើពន្ធ (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | ចំណូលមិនមែនសារពើពន្ធ(តួលេខ រតនាគារជាតិ) (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ **ពន្ធ និងអាករគយ:**+៣,៦%(តួលេខ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ) | (+១៨,១%) | ➢ **នេសាទ:**+១១,៨% | (+៤៧,៩%) |
| ➢ **ចំណូលពន្ធដារ:** +៦,0%(តួលេខ អគ្គនាយកដ្ឋានពន្ធដារ) | (+២៣,៤%) | ➢**រុក្ខាប្រមាញ់:**+៦៣,៣% | (+១២៥,៧%) |
| ➢ **កាស៊ីណូ :** -៥,៦% | (-0,៧%) | ➢**សម្បទានរ៉ែ:** -៧៧,៧% | (-៤៧,១%) |
| ➢ **អាជ្ញាបណ្ណក្នុងស្រុក :** +៦២,១% | (+៥៥,៤%) | ➢ **អាកាសចរណ៍ស៊ីវិល:**+៥៥,៧% | (+១២៦៥%) |
| ➢**កម្រៃគ្រប់គ្រងនិងទិដ្ឋាការនាំចេញ :** -៣៥,0% | (-៣១,៥%) | ➢**ផលទុននៃសកម្មភាពទេសចរណ៍:** | — |
| | | ➢**ប្រៃសណីយ៍ និងទូរគមនាគមន៍:**+២២៣,៧% | +៤៧,៧% |
| | | ➢**អាករស្នាក់ទុក:**+៤,៥% | (+៤៩,៣%) |

**២.២. ចំណាយថវិកាជាតិ:** អនុវត្តបាន ១១០១,៨ពាន់លានរៀល(*មធ្យមប្រចាំខែ ៥៨% នៃផែនការ*) ក្នុងនោះ ចំណាយចរន្ត ចំនួន ៩៥៣,៤ពាន់លានរៀល (*មធ្យមប្រចាំខែ ៧៩% នៃផែនការ*) និងចំណាយមូលធន១៤៨,៥ពាន់លានរៀល(តួលេខរតនាគារជាតិ)។

➢ចំណាយថវិកាជាតិកើនឡើង៤,២% ធៀបនឹងខែមុននិងកើនឡើង៦0,១%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះចំណាយចរន្តកើនឡើង៧,៤% ធៀបនឹងខែមុន និងកើនឡើង៦៥,៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

**២.៣. សមតុល្យថវិកាជាតិ** : **ថវិកាជាតិនាខែនេះមានអតិរេកចំនួន** ២,២ពាន់លានរៀល (តួលេខរតនាគារជាតិ)។

**ក្រាហ្វ២.២. ចំណាយថវិកាជាតិ ឆ្នាំ ២០១៣–២០១៥**

(ពាន់លានរៀល)




## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែកញ្ញាឆ្នាំ២០១៥មានលក្ខណៈដូចខាងក្រោម៖

➢រូបិយវត្ថុ$M_2$ មានចំនួន ៤៦៩៥៧ ពាន់លានរៀលកើនឡើង0,៥%ធៀបនឹងខែមុននិងកើនឡើង១៥,២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ការកើនឡើងនៃ$M_2$ជារួម បណ្ដាលមកពីការកើនឡើងនៃប្រាក់បញ្ញើមានកាលកំណត់និងសន្សំ0,១% និងប្រាក់បញ្ញើជារូបិយបណ្ណ0,៩%។

➢**នាខែនេះ ប្រាក់រៀលសរុប**នៅក្នុងនិងក្រៅធនាគារមាន **ចំនួន១៦,៥% និងប្រាក់បញ្ញើជា**រូបិយបណ្ណមានចំនួន ៨៣,៥% **នៃរូបិយវត្ថុ**$M_2$។

ក្រាហ្វ៣.១. សមាសធាតុរូបិយវត្ថុខែកញ្ញាឆ្នាំ២០១៥



*តារាង៣.១. សមាមាត្រចំនួនប្រាក់រៀល នៅក្នុងរូបិយវត្ថុ $M_2$ ឆ្នាំ២០១៥*

| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារ | ១៧,៩% | ១៨% | ១៧,៦% | ១៧,១% | ១៦,៥% | ១៦,១% | ១៦,៦% | ១៦,៨% | ១៦,៥% | | | |
| ប្រាក់រៀលក្រៅធនាគារ | ១៣,៦% | ១៣,៧% | ១៣,៥% | ១៣,៣% | ១២,៦% | ១២,២% | ១២,៤% | ១២,២% | ១៣,៤% | | | |

- **ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ**មានចំនួន ៤៦៨១លានដុល្លារ កើនឡើង១,៤%ធៀបនឹងខែមុន និងកើនឡើង១៥,២% **ធៀបនឹងខែដូចគ្នាឆ្នាំមុន។**
- **ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ** ក្នុងខែនេះមានចំនួន ១៣៦៧៣ពាន់លានរៀលថយចុះ ៣,៦%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៤,៣%**ធៀបនឹងខែដូចគ្នាឆ្នាំមុន។**

**តារាង៣.២.*ការផ្តល់ឥណទាននិង***អត្រាការប្រាក់ប្រចាំឆ្នាំ

| *ផ្តល់ដោយ* | *កញ្ញា២០១៥* | *សីហា២០១៥* | *កញ្ញា២០១៤* |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ(ពាន់លានរៀល) ក្នុងនោះ ជារៀល | ៤៤៣៤៦ | ៤៤៧៧១ | ៣៥៩៧២ ៤១៤ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(ពាន់លានរៀល) | — | ១០៧៩៩ | ៧៤១៧ |
| អត្រាការប្រាក់បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៦,៦៥% | ៦,៦៥% | ៥,៩៦% |
| អត្រាការប្រាក់កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១៦,១៩% | ១៦,២០% | ១៦,២១% |
| អត្រាការប្រាក់បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៤០% | ៤,៤០% | ៤,២៣% |
| អត្រាការប្រាក់កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១១,៦១% | ១១,៥៩% | ១១,៥១% |



## ៤) ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➡ក្នុងខែកញ្ញាឆ្នាំ២០១៥ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម៖

➢**កសិកម្ម**:

✓នេសាទសម្រេចបាន៦៣,៨ពាន់តោន កើនឡើង១៣%ធៀបនឹងខែមុន និងកើនឡើង៤១%**ធៀបនឹងខែដូចគ្នាឆ្នាំមុន។**

➢**រ៉ែ និងថាមពល**:

✓ អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ៥១៣,៦GWH មានការថយចុះ 0,9% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៣១%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន៣៨៧,៤GWH មានការកើនឡើង៤%ធៀបនឹងខែមុន និងកើនឡើង២៧%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢**ឧស្សាហកម្ម**:

✓ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន៦២៨,៣លានដុល្លារមានការថយចុះ២%ធៀបនឹងខែមុន និងកើនឡើង២២%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

**តារាង៤.១. ការចុះបញ្ជី**រោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម

| ប្រភេទ | ចំនួន –កញ្ញា២០១៥ | ចំនួន–សីហា២០១៥ | ចំនួន–កញ្ញា២០១៤ |
|---|---|---|---|
| ▪រោងចក្រថ្មីដែលបានចុះបញ្ជី | ២៧ | ១៨ | ១៤ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១៤២៦ | ១៤០០ | ១២៤២ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម(បើកថ្មី) | | | |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | | | |

➢សំណង់ (**ការអនុញ្ញាត**):

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ៧៦៦,១ពាន់ម² ថយចុះ៣០%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ២៧០% **ធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង** ៣២០,៤លានដុល្លារ ថយចុះ៤០%ធៀបនឹងខែមុនប៉ុន្តែកើនឡើង៣៥៦%បើ**ធៀបនឹងខែដូចគ្នាឆ្នាំមុន។ក្នុងនោះប្រភេទសំណង់ចម្បងៗមាន៖**

**តារាង៤.២. សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ**

| ប្រភេទ | ពាន់ម² –កញ្ញា២០១៥ | ពាន់ម² –សីហា២០១៥ | ពាន់ម² –កញ្ញា២០១៤ |
|---|---|---|---|
| ▪ លំនៅឋាន | ៦៣៣,៣ | ៨៦២,៩ | ១១៤ |
| ▪ ឧស្សាហកម្ម | ៩៣,៣ | ៥៣,១ | ៣៤,៣ |
| ▪ទេសចរណ៍ | ២៧,៦ | ១៩,៩ | ២២,៨ |
| ▪ពាណិជ្ជកម្ម | ៤,២ | ១១៣,៤ | ៣៣,៨ |
| ▪ផ្សេងៗ | ៣,២ | ២,៤ | 0 |
| អនុញ្ញាតសរុប | ៧៦៦,១ | ១០៥១,៥ | ២០៧,១ |

✓**ដូច្នេះ**សំណង់អនុញ្ញាតដែលពេញនិយមនាខែនេះគឺលំនៅដ្ឋាន ៨២,៧% និងឧស្សាហកម្ម ១២,២% នៃផ្ទៃក្រឡាសរុប។

➢ការងារ

**តារាង៤.៣. ការ**ស្វែងរកការងារនិង**ទទួលបានការងារ**

| ប្រភេទ | នាក់–កញ្ញា២០១៥ | នាក់–សីហា២០១៥ | នាក់–កញ្ញា២០១៤ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ (ទីភ្នាក់ងារជាតិមុខរបរនិងការងារ) | ៦៥៣ | ៧០៧ | ១៧០០៩ |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ៩៣៣៧ | ៨៩៦១ | ៩៥៨៧ |
| អ្នកទទួលបានការងារក្នុងប្រទេស | ៨០៩៦ | ៧៨៨៩ | ៨១៤២ |
| អ្នកទទួលបានការងារក្រៅប្រទេស | ១២៤១ | ១០៧២ | ១៤៤៥ |

➢**វិនិយោគ**

**តារាង**៤.៤.**គ**ម្រោងវិនិយោគអនុញ្ញាតដោយគ.វ.ក./ក.អ.ក. (ថ្មីនិងពង្រីក)

| ប្រភេទ | កញ្ញា២០១៥ | សីហា២០១៥ | កញ្ញា២០១៤ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ៤៧០,៨ | ៥១,៥ | ៣៨៨,៣ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ០ | ២៦ | ០ |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ៤១,៥<br>៣,០ | ២៥,៥<br>៣,១ | ៩២,៧<br>១,២ |
| វិស័យទេសចរណ៍ | ០ | ០ | ២៧៩,៩ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ៤២៩,៣ | ០ | ១៥,៧ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ១១ | ៨ | ១២ |
| បង្កើតការងារ (ពាន់នាក់) | ១២,២ | ៥,៦ | ១៦,៤ |

➢**សេវាកម្ម**

**តារាង៤.៥.ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម**

| ប្រភេទ | ចំនួន–កញ្ញា២០១៥ | ចំនួន–សីហា២០១៥ | ចំនួន–កញ្ញា២០១៤ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ២៤១ | ៤៩២ | ២៦៩ |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ១ | ៤ | ១៣ |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | | | ៣៥៦ |

➢**ទំនិញឆ្លងកាត់កំពង់ផែ**(សរុប៥កំពង់ផែ) មានចំនួន៥៩៥,៨ពាន់តោនកើនឡើង១%ធៀបនឹងខែមុននិងកើនឡើង១%**ធៀបនឹងខែដូចគ្នាឆ្នាំមុន**ក្នុងនោះ៖

**តារាង**៤.៦.ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ (ក្នុងវង់ក្រចកៈ បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន)

| | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញៈ-៩% | (+១២%) | ▪ កំពង់ផែស្រែអំបិល និងកោះកុងៈ+២៦% | (-២៧%) |
| ▪ កំពង់ផែកំពង់សោមៈ-៧% | (+១២%) | ▪ កំពង់ផែឧកញ៉ាម៉ុងៈ +៧៤% | (-២៦%) |

➢ការធ្វើដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

**តារាង**៤.៧.អ្នកដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

| ប្រភេទ | ចំនួន( ពាន់នាក់ ) | %∆ ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ៦,៧ | -៥៦% | -១៧% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ២៨,៥ | -២២% | +៥៤% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៣៧៩,៤ | -១៩% | +៨% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | | | |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា<br>✓ តាមផ្លូវអាកាស<br>✓ តាមផ្លូវគោក និងទឹក | | | |

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➡**ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ** ការនាំចូលនាខែកញ្ញាមានចំនួន ៤០៦៩ពាន់លានរៀល (ស្មើនឹង១០១៧លានដុល្លារ ស.រ.អា.)ថយចុះ៨,២% ធៀបនឹងខែមុនប៉ុន្តែកើនឡើង១,៥%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ៖

**តារាង៥.១.បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន**

| ទំនិញ | %∆ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %∆ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | +៨,៦% | +១២,១% | រថយន្តសរុប (ព.ល.រ) | +២០,៣% | +៣៥,៩% |
| ប្រេងម៉ាស៊ូត | -១,៤% | -០,០% | រថយន្តសរុប (គ្រឿង) | +១៨,៧% | +៥២% |
| ឧស្ម័ន | +៣៥,៤% | +៤៩,៣% | ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | +៣៦% | -៤៦,៦% |
| អគ្គិសនីនាំចូល | -៣,៤% | +៧,៦% | ម៉ូតូ (គ្រឿង) | -៣០,៦% | -៣៦,៣% |
| ដែកសំណង់ | +១៧៥,៩% | +៥១៨,៨% | អង្ករ | -៣៣,៥% | +៣៣,៧% |
| ស៊ីម៉ង់ត៍ | -១,៣% | -២០% | ផ្លែឈើនិងបន្លែ | -២០,៣% | -១២,១% |
| គ្រឿងអេឡិចត្រូនិក | -៤,៧% | +៨២% | ជីនិងថ្នាំកសិកម្ម | +៣១,៧% | -៨,១% |
| | | | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | -៤,៩% | +២៨,៧% |

➡ **ការនាំចេញ ខែកញ្ញាឆ្នាំ២០១៥ មានចំនួន៣១០៩,៥ពាន់លានរៀល ស្មើនឹង៧៧៧,៣លានដុល្លារ ស.រ.អា.** (៧៦,៤% នៃការនាំចូល)ថយចុះ១១,៥% ធៀបនឹងខែមុនប៉ុន្តែកើនឡើង៣១,៩%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

**តារាង៥.២.បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន**

| ទំនិញ | %∆ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %∆ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ផលិតផលឈើកែច្នៃ | -១៩,៩% | -៩៤,៥% | ផលិតផលនេសាទ | -២១,៦% | -៦២,២% |
| វាយនភណ្ឌនិងស្បែកជើង | -១៨,៥% | +២៩,៤,% | កៅស៊ូ | +៤,៨% | +៥៧,៣% |
| អង្ករ | +១៧,២% | +០,១% | | | |

➡ក្នុងខែកញ្ញានេះជញ្ជីងពាណិជ្ជកម្មមានឱនភាពចំនួន៩៥៩,៦ពាន់លានរៀលស្មើនឹង២៣៩,៩លានដុល្លារ ស.រ.អា.។

## ៦) ការប្រែប្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែកញ្ញាឆ្នាំ២០១៥នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចក្នុងតារាងខាងក្រោម។

**តារាង៦.១. បម្រែមប្រួលគួរឲ្យចាប់អារម្មណ៍ នៃសូចនាករមួយចំនួន**

| ល.រ | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | ថ្លៃត្រីស្រស់ | +០,៩% | +៨,៦% | — |
| ២ | ថ្លៃបន្លែ | +១,៣% | +៧,៦% | — |
| ៣ | ការនាំចូលរថយន្ត (គ្រឿង) | +១៨,៧% | +៥២,០% | ក្នុងខែកញ្ញានេះ ការនាំចូលរថយន្ត សរុប មានចំនួន ៦០៥០ គ្រឿង។ |

## ៧) សេចក្តីសន្និដ្ឋាន

១) បច្ចុប្បន្ន កម្ពុជានៅតែមានការពឹងផ្អែកខ្លាំងលើចំណូលពន្ធគយ ដែលនឹងត្រូវកាត់បន្ថយក្នុងរយៈពេលខ្លីខាងមុខ នៅពេលដែលសមាហរណកម្មនៃសមាគមសេដ្ឋកិច្ចអាស៊ានចូលជាធរមាន។ ក្នុងគោលបំណងបង្កើនប្រសិទ្ធភាពនិងសមធម៌នៃការប្រមូលពន្ធ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ដែលក្នុងនោះមានរំលេចអំពីកំណែទម្រង់ប្រព័ន្ធពន្ធដារ ដែលតម្រូវឲ្យធុរកិច្ចគ្រប់ខ្នាត (តូច មធ្យម និងធំ) បង់ពន្ធតាមរបបស្វ័យប្រកាស (របបពិត) ចំណែកឯរបបម៉ៅការនឹងត្រូវលុបចោល។

២) តួលេខនាំចូលរថយន្តក្នុងពីរឆ្នាំចុងក្រោយនេះ មានទំហំធំគួរឲ្យកត់សម្គាល់ទន្ទឹមនឹងនោះ នៅទីក្រុងភ្នំពេញ ការកកស្ទះចរាចរណ៍ និងការបំពុលបរិស្ថាន ក្លាយជាបញ្ហាចម្បងដែលគួរយកចិត្តទុកដាក់។ បើកំណើនយានយន្តនៅតែខ្ពស់បែបនេះ ទោះបីជាមានការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធយ៉ាងណាក៏ដោយ ការធ្វើចរាចរនៅលើដងផ្លូវនឹងនៅតែជាកង្វល់ធ្ងន់ធ្ងរដដែល។

៣) យោងតាមតួលេខផ្លូវការ កម្ពុជាបាននាំចេញអង្ករប្រហែល ៣៧០ពាន់តោន ក្នុង៩ខែដើមឆ្នាំ ២០១៥ កើនឡើងពី ២៦០ ពាន់តោន នៃអំឡុងពេលដូចគ្នា ឆ្នាំ២០១៤។ តួលេខនេះ នៅទាបជាងផែនការជាតិស្តីពីការនាំចេញអង្ករ១លានតោនក្នុងមួយឆ្នាំ ប៉ុន្តែកម្ពុជាក៏នាំចេញស្រូវទៅប្រទេសជិតខាងយ៉ាងច្រើន បើបូកបញ្ចូលគ្នាតួលេខទាំងពីរ ការនាំចេញអង្កររបស់កម្ពុជាមានបរិមាណប្រហាក់ប្រហែលនឹងផែនការនោះហើយ។ យ៉ាងណាមិញ បញ្ហាប្រឈមក្នុងការសម្រេចបានផែនការនេះ មានជាអាទិ៍៖ (១) ថ្លៃមិនមានភាពប្រកួតប្រជែង,(២) កង្វះទុន និងអត្រាការប្រាក់ខ្ពស់ (៣) មិនទាន់មានស្តង់ដារ ដោយខ្វះមន្ទីរពិសោធន៍កាកសំណល់គីមីក្នុងអង្ករ និងម៉ាស៊ីនកិនស្រូវទំនើបខ្នាតអន្តរជាតិ, និង (៤) កំពង់ផែតូចចង្អៀត ការដឹកជញ្ជូនមានតម្លៃខ្ពស់។

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា
## ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច
## និងវប្បធម៌ ប្រចាំខែតុលា ឆ្នាំ២០១៥

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/១០/១៥ ម៉ោង០៩:៣០នាទី | ដឹកនាំគណៈកម្មការ ចុះពិនិត្យការងារសាងសង់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។ |
| ២ | ០២/១០/១៥ ម៉ោង០៩:៣០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយតំណាងក្រុមហ៊ុន Union Development Group នៅបន្ទប់ឯកឧត្តម ប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ០៦/១០/១៥ ម៉ោង០៨:០០នាទី | ចូលរួមជាគណៈអធិបតី ក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវអគារជំងឺទូទៅ មន្ទីរពេទ្យបង្អែកកោះអណ្តែត អំណោយរបស់ប្រជាជនជប៉ុន ក្រោមគម្រោងគូសាណូណេតាមរយៈស្ថានទូតជប៉ុន និងអគារសម្ភពអំណោយរបស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** និងលោកជំទាវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តតាកែវ និងលោកជំទាវ នៅមន្ទីរពេទ្យបង្អែក នៃស្រុកប្រតិបត្តិកោះអណ្តែត ។ |
| ៤ | ០៦/១០/១៥ ម៉ោង១៥:០០នាទី | ចូលរួមជាគណៈអធិបតី ក្នុងពិធីប្រកាសកែសម្រួលបំពេញបន្ថែមសមាសភាពគណៈកម្មាធិការគណបក្ស ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមការងារថ្នាក់កណ្តាល ចុះជួយខេត្តតាកែវ នៅមន្ទីរគណៈកម្មាធិការគណបក្សខេត្តតាកែវ។ |
| ៥ | ០៧/១០/១៥ ម៉ោង១១:០០នាទី | ចូលរួមជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងការទទួលជួបសំណេះសំណាលជាមួយមន្ត្រីរាជការទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៦ | ០៧/១០/១៥ ម៉ោង១៥:៣០នាទី | ទទួលជួបប្រជុំពិភាក្សាការងារជាមួយឯកឧត្តម **ហែម សាឯម** នៅបន្ទប់ឯកឧត្តម ប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា
## ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែតុលា ឆ្នាំ២០១៥ (ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៧ | ០៨/១០/១៥<br>ម៉ោង០៩:១៥នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើៈ<br>១-សេចក្តីព្រាងច្បាប់ ស្តីពីទូរគមនាគមន៍។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការបោះពុម្ពសារព្រមានសុខភាពជាភាសាខ្មែរ និងជារូបភាពលើកញ្ចប់ ផលិតផលថ្នាំជក់។<br>៣-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៨ | ០៩/១០/១៥<br>ម៉ោង០៨:៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោមៈ<br>១-សេចក្តីព្រាងច្បាប់ ស្តីពីទូរគមនាគមន៍។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការបោះពុម្ពសារព្រមានសុខភាពជាភាសាខ្មែរ និងជារូបភាពលើកញ្ចប់ ផលិតផលថ្នាំជក់។<br>៣-បញ្ហាផ្សេងៗសំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រីដើម្បីស្នើសុំសច្ចាប័ន ពីស្ថាប័ននីតិប្បញ្ញត្តិលើៈ<br>៣.១ កិច្ចព្រមព្រៀងស្តីពីការបង្កើតធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី។<br>នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ៩ | ១៥/១០/១៥<br>ម៉ោង០៧:៣០នាទី | ចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងពិធីដាក់កម្រងផ្កានៅស្តូបព្រះបរមរូប **"ព្រះបរមរតនកោដ្ឋ"** ដើម្បីគោរពព្រះវិញ្ញាណក្ខន្ធ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ **"ព្រះបរមរតនកោដ្ឋ"** គម្រប់ខួប ៣ឆ្នាំ នៅមណ្ឌល សួនច្បារខាងកើតវិមានឯករាជ្យ និងបន្ទាប់មក នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១០ | ១៩/១០/១៥<br>ម៉ោង០៧:៣០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីប្រគល់សញ្ញាបត្រ ថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និង ថ្នាក់បណ្ឌិត ជូនដល់និស្សិត សាកលវិទ្យាល័យ វេស្ទើន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង សម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅវិទ្យាស្ថានជាតិអប់រំ។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែតុលា ឆ្នាំ២០១៥ (តចប់)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១១ | ២០/១០/១៥<br>ម៉ោង០៩:៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦។<br>២-សេចក្តីព្រាងច្បាប់ ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រង ឆ្នាំ២០១៤។<br>៣-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១២ | ២១/១០/១៥<br>ម៉ោង០៨:៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦។<br>២-សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រង ឆ្នាំ២០១៤។<br>៣-បញ្ហាផ្សេងៗ។<br>នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១៣ | ២១/១០/១៥<br>ម៉ោង១៥:៣០នាទី | ដឹកនាំកិច្ចប្រជុំជាមួយមន្ត្រីឯកទេសផ្នែកដោះស្រាយវិវាទនៃការិយាល័យ CAO នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៤ | ២២/១០/១៥<br>ម៉ោង០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធបើកឲ្យប្រើប្រាស់ជាផ្លូវការ ស្ពានមិត្តភាពកម្ពុជា-ចិន ជ្រោយចង្វារទី២ ក្រោមហិរញ្ញប្បទានពីរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាមានិតចិន និងរង្វង់មូលត្រើយខាងលិច-ត្រើយខាងកើតសាងសង់ដោយសាលារាជធានីភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅភូមិដើមគ សង្កាត់ជ្រោយចង្វារ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ។ |
| ១៥ | ២២/១០/១៥<br>ម៉ោង១៤:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រកាសផ្សព្វផ្សាយ និងដាក់ឲ្យអនុវត្តគោលនយោបាយជាតិ ស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១៦ | ២៧/១០/១៥<br>ម៉ោង០៨:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធ "ស្តូបមិត្តភាពកម្ពុជា-រុស្ស៊ី" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។ |



រូបភាពក្នុងកិច្ចប្រជុំស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
នៅទីស្តីការគណៈរដ្ឋមន្ត្រី





រូបភាពក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ
នៅទីស្ដីការគណៈរដ្ឋមន្ត្រី



# ព្រឹត្តិបត្រព័ត៌មាន



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in